អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ គុណសម្បត្តិរបស់សម្តេចហួត-តាត

website ៖ www.hoksavann.org

ថ្ងៃទី២៧ មិថុនា ២០០៩



ពុទ្ធសាសនិកជនខ្មែរជាទូទៅតែងតែចាំយ៉ាងច្បាស់ និងនឹកគុណព្រះមហាសុមេធាធិបតី ជោតញាណោជួន-ណាត សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ថាព្រះអង្គមានគុណយ៉ាងធ្ងន់ចំពោះជាតិខ្មែរនិងព្រះពុទ្ធសាសនា ជាពិសេសខាងវិស័យអក្សរសាស្ត្រ ។ ប៉ុន្តែគេភ្លេចនឹកគុណសម្តេចព្រះមហាសុមេធាធិបតីហួត-តាត ព្រះសង្ឃនាយកគណៈមហានិកាយ ដែលព្រះអង្គមានគុណដ៏ធ្ងន់ចំពោះជាតិនិងចំពោះព្រះពុទ្ធសាសនា ជាពិសេសចំពោះការបង្កើតពុទ្ធិកសិក្សា ដែលកាលព្រះអង្គត្រូវខ្មែរក្រហមយកទៅធ្វើគតនោះ ព្រះអង្គមានឋានៈជាសម្តេចសង្ឃនាយកផង ជាអគ្គាធិការនៃពុទ្ធិកសិក្សាផង ។

ក្នុងឋានៈជាសមណនិស្សិតមួយរូបនាសម័យនោះ យើងចាំបានថា សម្តេចហួត-តាតបានមានព្រះសង្ឃដីកាថា ការបង្កើតឲ្យព្រះសង្ឃសមណសិស្សនិងសមណនិស្សិតរៀនវិជ្ជាព្រះពុទ្ធសាសនាផងនិងផ្លូវលោកផង មានប្រយោជន៍សំខាន់ណាស់ បើលោកនៅបួសជាព្រះសង្ឃ លោកអាចយល់ដឹងអំពីរបៀបរស់នៅរបស់គ្រហស្ថ បើលោកអស់និស្ស័យលាចាកសិក្ខាបទទៅវិញ ក៏បានជាពលរដ្ឋដ៏ល្អរបស់ជាតិ ។ ពុទ្ធិកសិក្សាសម័យនោះចាត់ជាពុទ្ធិកសិក្សា បឋមសិក្សារៀនបីឆ្នាំ ពុទ្ធិកមធ្យមសិក្សាបឋមភូមិ (ឌីប្លូម) រៀនបួនឆ្នាំ ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) រៀនប្រាំមួយឆ្នាំ និងពុទ្ធិកឧត្តមសិក្សា (បរិញ្ញាប័ត្រ) បន្តបួនឆ្នាំទៀត ។ ពុទ្ធិកសិក្សានោះមានរៀនព្រះពុទ្ធសាសនា បាលី សំស្ក្រឹត និងវិជ្ជាផ្លូវលោក មានរៀនស្មើរគ្រប់មុខវិជ្ជាដូចសិក្សាក្នុងក្រសួងអប់រំ ហើយមានរៀនភាសាបារាំង និងអង់គ្លេសផង ។

នៅថ្ងៃ១៧មេសា១៩៧៥ ក្រោយពេលដែលខ្មែរក្រហមបានវាយលុកចូលមកដល់ភ្នំពេញតែប៉ុន្មានម៉ោងប៉ុណ្ណោះ ខ្មែរក្រហមបានដេញប្រជាពលរដ្ឋនិងព្រះសង្ឃចេញពីទីក្រុងភ្នំពេញ ។ ពេលនោះគ្មានអ្នកណាជួយអ្នកណាបានឡើយ ព្រះសង្ឃដែលធ្លាប់គេគោរពនិងគេជួយឧបត្ថម្ភនោះ ព្រះអង្គត្រូវដោះស្រាយដោយព្រះអង្គឯង ដោយនិមន្តចេញពីវត្ត ក្រោមចុងកាណុងរបស់ពួកខ្មែរក្រហម ។ ព្រះសង្ឃចាស់ជរាបានត្រូវសុគតតាមផ្លូវ ព្រះសង្ឃខ្លះពិបាកពេល បានសឹកតាមផ្លូវ ព្រះសង្ឃខ្លះបានខំតស៊ូរស់នៅក្នុងផ្នួសរង់ចាំពេលវេលា ។ តាមផែនការរបស់ពួកខ្មែរក្រហម ត្រូវផ្សឹកព្រះសង្ឃទាំងអស់ក្នុងប្រទេសកម្ពុជាទាំងមូល ។ ដូច្នេះហើយបានជាពេលដែលខ្មែរក្រហមបានចូលមកដល់ភ្នំពេញ ខ្មែរក្រហមបានចាប់សម្តេចហួត-តាតនិងមន្ត្រីសង្ឃដទៃទៀត យកទៅធ្វើគតជាបន្តបន្ទាប់គ្នា ។ តាមពត៌មានថា សម្តេចហួត-តាតបានត្រូវពួកខ្មែរក្រហមយកទៅឧដុង្គ ក្រោយមកបានត្រូវពួកវាធ្វើគត ។ តាមពត៌មានតែគួរឲ្យជឿបានថា មុននឹងសុគត ពួកវាបានសួរ ផ្ចាញ់ផ្ចាល បង្អត់ចង្ហាន់ ហើយចងអូសតាមឡានរហូតដាច់ខ្យល់ ។ លក្ខណៈដ៏សាហាវនេះបញ្ជាក់ថា សង្គ្រាមប្រទេសកម្ពុជាជាសង្គ្រាមគំនុំសងសឹក ព្រោះសម្តេចហួត-តាតនិងមន្ត្រីសង្ឃដទៃទៀត គាំទ្រសាធារណរដ្ឋខ្មែររបស់លោកលន់-នល់ ក្រាញនៅក្នុងតំបន់ខ្មាំងដែលគេត្រូវកំទេច ។ នេះជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រោះប្រព្រឹត្តអំពើឧក្រិដ្ឋទៅលើអ្នកចាញ់ ។

ប្រវត្តិសង្ខេបរបស់សម្តេចហួត-តាត (វជិរប្បញ្ញោ) ប្រសូតនៅឆ្នាំ១៨៩១ នៅភូមិផ្សារឧដុង្គ សង្កាត់វាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ សម្តេចហួត-តាតជាបុត្រទី៣ ក្នុងបណ្តាបុត្រទាំងបួននាក់ ។ មាតានាមង៉ែត បិតានាមហុក-សេង ហៅហួត ។ ព្រះជន្មបាន១៣ឆ្នាំ ព្រះអង្គបានបួសជាសាមណេរ ។ ហើយនៅឆ្នាំ១៩១២ ក្នុងព្រះជន្ម២០ឆ្នាំ ព្រះអង្គបានឧបសម្បទាជាភិក្ខុក្នុងសំណាក់ព្រះសង្ឃរាជព្រះនាមទៀង វត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ ព្រះអង្គបានសិក្សាព្រះបរិយត្តិ គឺព្រះត្រៃបិដក មានចំណេះយ៉ាងជ្រៅជ្រះ ជាពិសេសនៅឆ្នាំ១៩២២ រាជការអាណាព្យាបាលបារាំង បានបញ្ជូនព្រះអង្គជាមួយសម្តេចជួន-ណាត ឲ្យទៅរៀនភាសាសំស្ក្រឹត អក្សរថ្មរបស់ខ្មែរបុរាណ និងប្រវត្តិព្រះពុទ្ធសាសនានៅសាលាបារាំងចុងបូព៌ាប្រទេស នៅទីក្រុងហាណូយប្រទេសវៀតណាម ដែលមានលោក ល្វី-ហ្វីណូត៍ ជាចាងហ្វាងនៃសាលានោះ ជាគ្រូរបស់ព្រះអង្គ ។ សម្តេចហួត តាតបានត្រូវរាជការបារាំង តែងតាំងជាសាស្ត្រាចារ្យបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃផ្លាស់មកជាពុទ្ធិកវិទ្យាល័យ ។

នៅឆ្នាំ១៩១៩ សម្ដេចហួត-តាតបានត្រូវរដ្ឋាភិបាលតែងតាំងជាសមាជិកនៃក្រុមជំនុំរៀបចំបង្កើតវចនានុក្រមខ្មែរ ។ នៅឆ្នាំ១៩៣៥ ព្រះអង្គបានត្រូវចាត់ឲ្យទៅបង្រៀនភាសាខ្មែរនិងភាសាសំស្ក្រឹតចំពោះនិស្សិតនៅវិទ្យាល័យស៊ីសុវត្ថិក្រុងភ្នំពេញ ។ ក្នុងឆ្នាំដដែលនោះ ព្រះអង្គបានត្រូវទទួលមុខការថ្មីមួយទៀត ជាអធិបតីរងនៃក្រុមជំនុំព្រះត្រៃបិដកជាភាសាខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ ។ នៅឆ្នាំ១៩៤៨ សម្ដេចហួត-តាតបានឡើងសមណសក្តិជា ព្រះពោធិវង្ស ។ នៅឆ្នាំ១៩៥៥ ព្រះអង្គបានត្រូវតែងតាំងជាអគ្គាធិការនៃពុទ្ធិកសិក្សា ។ នៅឆ្នាំ១៩៦៤ ព្រះអង្គបានត្រូវទទួលនាទីជាសម្ដេចព្រះពោធិវង្ស ។ នៅឆ្នាំ១៩៦៨ ព្រះអង្គបានត្រូវតែងតាំងជាសកលវិទ្យាធិការនៃពុទ្ធិកសកលវិទ្យាល័យ ។ នៅឆ្នាំ១៩៦៩ ព្រះអង្គបានត្រូវតែងតាំងជា សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ជំនួសសម្ដេចជួន-ណាត ដែលសោយទិវង្គត ។

សម្ដេចហួត-តាតបាននិពន្ធសៀវភៅជាច្រើន ជាពិសេសបានប្រែគម្ពីរដីកាពីបាលីសំស្ក្រឹតមកជាភាសាខ្មែរ ។

តាមការស្រាវជ្រាវអំពីប្រវត្តិនិងសកម្មភាពរបស់សម្ដេចហួត-តាត ដោយសេចក្ដីសង្ខេបមកនេះបញ្ជាក់ថា សម្ដេចហួត-តាតបានបំពេញព្រះសកម្មភាពយ៉ាងច្រើនជួយសង្គមខ្មែរខាងវិស័យព្រះពុទ្ធសាសនា ជាពិសេសជាអ្នកផ្ដើមគំនិតនិងបំពេញសកម្មភាពជួយពុទ្ធិកសិក្សា គឺការសិក្សារបស់ព្រះសង្ឃ ឲ្យមានចំណេះខាងផ្លូវធម៌និងផ្លូវលោក មានសកម្មភាពប្រហាក់ប្រហែលគ្នានឹងសម្ដេចព្រះសង្ឃរាជជួន-ណាតដែរ ។

សម្ដេចហួត-តាតត្រូវទទួលរងគ្រោះរហូតត្រូវគេធ្វើគតយ៉ាងសាហាវបំផុតនេះ ដោយការសងសឹករបស់អ្នកនយោបាយ និងរបស់ពួកទមិឡឥតសាសនា ។ ដូច្នេះពុទ្ធិសាសនិកជនខ្មែរទាំងគ្រហស្ថទាំងព្រះសង្ឃ ជាពិសេសព្រះសង្ឃសមណសិស្ស និងសមណនិស្សិត គប្បីសំដែងការដឹងគុណចំពោះសម្ដេចហួត-តាត ដែលផ្ដល់ប្រយោជន៍យ៉ាងច្រើនចំពោះជាតិ និងចំពោះព្រះពុទ្ធសាសនា ដោយជ្រើសរើសថ្ងៃនិងខែណាមួយរៀងរាល់ឆ្នាំ ធ្វើបុណ្យរំលឹកគុណចំពោះព្រះអង្គ និងព្រះសង្ឃដទៃទៀត ព្រមទាំងប្រជាពលរដ្ឋខ្មែរ ដែលត្រូវពួកទមិឡឥតសាសនាធ្វើគតនិងសម្លាប់យ៉ាងសាហាវព្រៃផ្សៃ ។ បុណ្យរំលឹកគុណអាចធ្វើក្នុងថ្ងៃកំណើតរបស់ព្រះអង្គក៏បាន ។ តាមការស្រាវជ្រាវ សម្ដេចហួតតាតប្រសូតថ្ងៃអាទិត្យ១៥កើត ខែបុស្ស ឆ្នាំរោងចត្វាស័ក ព.ស.២៤៣៤ គ.ស.១៨៩១ ។ ក្នុងសុរិយគតិ មិនឃើញថ្ងៃទីនិងខែណាទេ ឃើញតែឆ្នាំកំណើតរបស់ព្រះអង្គ គឺឆ្នាំ១៨៩១ ។៚